# គោលនយោបាយជំនួយហិរញ្ញវត្ថុរបស់ Lifespan — សេចក្តីសង្ខេបជាភាសាសាមញ្ញ

គោលនយោបាយជំនួយហិរញ្ញវត្ថុរបស់ Lifespan (FAP) ផ្តល់ដល់អ្នកជំងឺដែលមានសិទ្ធិទទួលបានសេវាកម្មសង្គ្រោះបន្ទាន់ និងសេវាកម្មថែទាំសុខភាពចាំបាច់ផ្នែកវេជ្ជសាស្រ្តដទៃទៀតដែលបញ្ចុះតម្លៃដោយភាគ ឬទាំងស្រុងដែលត្រូវបានផ្តល់ជូនដោយស្ថាប័នបុត្រសម្ព័ន្ធរបស់ Lifespan។ ស្ថាប័នបុត្រសម្ព័ន្ធទាំងនេះរួមមានមន្ទីរពេទ្យ Rhode Island Hospital មន្ទីរពេទ្យ Miriam Hospital មន្ទីរពេទ្យ Newport Hospital មន្ទីរពេទ្យ Emma Pendleton Bradley Hospital (មន្ទីរពេទ្យ Bradley Hospital) Lifespan Physician Group, Inc., Gateway Healthcare, Inc., និងអង្គភាពដែលជាប់ពាក់ព័ន្ធសំខាន់ណាមួយដែលតពីនេះទៅហៅថា Lifespan។ អ្នកជំងឺដែលស្វែងរកជំនួយហិរញ្ញវត្ថុត្រូវតែដាក់ពាក្យសុំកម្មវិធីនេះ។ ព័ត៌មានលម្អិតស្តីអំពីគោលនយោបាយ និងដំណើរការដាក់ពាក្យត្រូវបានសង្ខេបនៅក្នុងទីនេះ។

សេវាកម្មដែលមានសិទ្ធិទទួលបាន៖ សេវាកម្មដែលមានសិទ្ធិទទួលបានរួមមានសេវាកម្មសង្គ្រោះបន្ទាន់ ឬសេវាកម្មថែទាំសុខភាពដែលចាំបាច់ផ្នែកវេជ្ជសាស្រ្តដទៃទៀតដែលត្រូវបានផ្តល់ជូន និងត្រូវបានចេញវិក្កយបត្រគិតថ្លៃដោយ Lifespan។ សូមកត់សម្គាល់ថា FAP អនុវត្តន៍ចំពោះតែសេវាកម្មដែលត្រូវបានចេញវិក្កយបត្រគិតថ្លៃដោយ Lifespan តែប៉ុណ្ណោះ។ សេវាកម្មដទៃផ្សេងទៀតដែលត្រូវបានចេញវិក្កយបត្រគិតថ្លៃដាច់ដោយឡែកដោយអ្នកផ្តល់សេវាកម្មថែទាំសុខភាពដទៃផ្សេងទៀតដូចជាគ្រូពេទ្យ ឬមន្ទីរពិសោធន៍ដែលមិនជាប់ជាបុត្រសម្ព័ន្ធជាមួយ Lifespan ទេនោះគឺមិនមានសិទ្ធិទទួលបាននៅក្រោម FAP នោះឡើយ។

អ្នកជំងឺដែលមានសិទ្ធិទទួលបាន៖ ជាទូទៅ ជនដែលមានសិទ្ធិទទួលបានរួមមានបុគ្គលដែលប្រាក់ចំណូលគ្រួសារស្ថិតនៅ ឬទាបជាង 300% នៃគោលការណ៍ណែនាំអំពីភាពក្រីក្ររបស់សហព័ន្ធ (FPG) ដូចដែលបានកំណត់ឡើងដោយក្រសួងសុខាភិបាល និងសេវាកម្មមនុស្សរបស់សហរដ្ឋអាមេរិក។ ភាពមានសិទ្ធិទទួលបានសម្រាប់ជំនួយហិរញ្ញវត្ថុ អនុញ្ញាតឲ្យអ្នកជំងឺដែលមានសិទ្ធិទទួលបានការបញ្ចុះតម្លៃពេញទាំងស្រុង ឬដោយភាគដល់ការថែទាំរបស់ពួកគាត់។ អ្នកជំងឺដែលមានសិទ្ធិទទួលបាននឹងទទួលបានជំនួយហិរញ្ញវត្ថុដែលនឹងមិនត្រូវបានគេចេញវិក្កយបត្រគិតថ្លៃលើសពី “ចំនួនដែលជាធម្មតាត្រូវបានចេញវិក្កយបត្រគិតថ្លៃ” (AGB) នោះឡើយ។ ដោយប្រើប្រាស់វិធីសាស្រ្តទំនងនឹងកើតមាន AGB ដូចដែលត្រូវបានកំណត់ដោយសេវាកម្មប្រាក់ចំណូលផ្ទៃក្នុង §501(r) ត្រូវបានកំណត់ថាជាចំនួនដែលកម្មវិធី Medicare ឬ Medicaid នឹងសងមន្ទីរពេទ្យសម្រាប់ការថែទាំដែលត្រូវបានចេញវិក្កយបត្រគិតថ្លៃ (រួមមានទាំងចំនួនដែលនឹងត្រូវបានសងដោយកម្មវិធី Medicare ឬ Medicaid និងចំនួនដែលអត្ថាគាហកនឹងទទួលខុសត្រូវដោយផ្ទាល់ខ្លួនក្នុងការបង់ទូទាត់នៅក្នុងទម្រង់ជាសហបង់ទូទាត់ សហធានារ៉ាប់រង និងការកាត់កង)

ប្រសិនបើអ្នកជំងឺជាអត្ថាគាហកនៃកម្មវិធីបង់ចំណាយសម្រាប់សេវាកម្មរបស់កម្មវិធី Medicare ឬ Medicaid។ កម្រិតជំនួយហិរញ្ញវត្ថុដែលអាចអនុញ្ញាតបានសម្រាប់អ្នកជំងឺដែលមានសិទ្ធិទទួលបានគឺមានដូចតទៅនេះ៖

- ជំនួយហិរញ្ញវត្ថុទាំងស្រុងត្រូវបានផ្តល់ជូនដល់អ្នកជំងឺដែលមានចំណូលគ្រួសាររបស់គាត់ស្ថិតនៅក្នុងរង្វង់ 0% ទៅ 200% នៃ FPG (គោលការណ៍ណែនាំអំពីភាពក្រីក្រសហព័ន្ធ)។ មិនមានចំនួនណាមួយនៃសេវាកម្មដែលផ្តល់ជូនដោយ Lifespan ត្រូវបានចេញវិក្កយបត្រគិតប្រាក់ពីអ្នកជំងឺឡើយនៅក្នុងដំណើររឿងបែបនេះ។

- ជំនួយហិរញ្ញវត្ថុជាអន្លើត្រូវបានផ្តល់ជូនទៅកាន់អ្នកជំងឺដែលមានចំណូលគ្រួសារស្ថិតនៅក្នុងរង្វង់ 201%-300% នៃ FPG (នៃគោលការណ៍ណែនាំអំពីភាពក្រីក្រសហព័ន្ធ)។ សម្រាប់អ្នកជំងឺដែលមានប្រាក់ចំណូលស្ថិតនៅក្នុងរង្វង់នៃចន្លោះនេះ Lifespan នឹងប្រើប្រាស់ AGB ជាចំនួនអតិបរមាដែលអាចចេញវិក្កយបត្រគិតថ្លៃពីអ្នកជំងឺសម្រាប់សេវាកម្មដែលត្រូវបានផ្តល់ជូនដោយ Lifespan។

កត្តាមួយផ្សេងទៀតដែលត្រូវបានពិចារណានៅពេលកំណត់ជំនួយហិរញ្ញវត្ថុគឺទ្រព្យសកម្មរាវដែលកាន់កាប់ជាកម្មសិទ្ធិដោយអ្នកជំងឺ។ ឧទាហរណ៍នៃប្រភេទបែបអស់ទាំងនេះនៃទ្រព្យសកម្មរួមមានសាច់ប្រាក់សុទ្ធ ឬទ្រព្យសកម្មផ្សេងៗទៀតដែលអាចប្តូរបានយ៉ាងងាយស្រួលទៅជាសាច់ប្រាក់សុទ្ធ។ កម្មសិទ្ធិភាពនៃចំនួនជាក់លាក់មួយនៃទ្រព្យសកម្មរាវអាចនឹងនាំមកនូវការបដិសេធមិនផ្តល់ជំនួយហិរញ្ញវត្ថុ បើទោះបីជាអ្នកជំងឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្រោមការកំណត់ FPG (គោលការណ៍ណែនាំអំពីភាពក្រីក្រសហព័ន្ធ) ដែលត្រូវបានបកស្រាយរៀបរាប់មុននេះក៏ដោយ។ ប្រសិនបើអ្នកជំងឺបានលាតត្រដាងនៅក្នុងពាក្យសុំជំនួយហិរញ្ញវត្ថុរបស់ពួកគេថាគេគ្មានប្រាក់ចំណូលគ្រួសារ នោះផ្នែកសេវាកម្មហិរញ្ញវត្ថុអ្នកជំងឺរបស់ Lifespan នឹងទាមទារព័ត៌មានដែលគាំទ្រថាតើតម្រូវការប្រចាំថ្ងៃត្រូវបានបំពេញបានដោយរបៀបណា។ Lifespan ធ្វើការត្រួតពិនិត្យឡើងវិញនូវរាល់គ្រប់ពាក្យសុំដែលបំពេញរួចរាល់ទាំងអស់ដែលត្រូវបានដាក់ជូន ហើយកំណត់ភាពមានសិទ្ធិទទួលជំនួយហិរញ្ញវត្ថុដោយស្របទៅតាម FAP របស់ Lifespan។ ពាក្យសុំដែលមិនពេញលេញគ្រប់ជ្រុងជ្រោយនឹងមិនត្រូវបានពិចារណាឡើយ។ តែយ៉ាងនេះក្តី អ្នកដាក់ពាក្យសុំដែលដាក់ជូនពាក្យសុំមិនពេញលេញគ្រប់ជ្រុងជ្រោយរបស់ខ្លួនត្រូវបានជម្រាបជូនដំណឹងអំពីស្ថានភាពនេះហើយត្រូវបានផ្តល់នូវឱកាសដើម្បីផ្តល់នូវឯកសារ/ព័ត៌មានដែលមិនទាន់ដាច់ស្រេច ឬដែលបាត់ដែលចាំបាច់ដើម្បីបំពេញដំណើរការដាក់ពាក្យសុំ។

របៀបដាក់ពាក្យសុំ៖ FAP និងទម្រង់បែបបទពាក្យសុំដែលពាក់ព័ន្ធរបស់ Lifespan អាចនឹងទទួលយកបាន បំពេញ និងដាក់បញ្ជូនដូចតទៅនេះ៖

1. FAP និងឯកសារពាក្យសុំរបស់ Lifespan គឺអាចរកបានដោយការមកទទួលយកដោយផ្ទាល់នៅទីតាំងណាមួយនៃទីតាំងស្ថាប័នមន្ទីរពេទ្យរបស់ Lifespan ដូចខាងក្រោម៖

   - មន្ទីរពេទ្យ Rhode Island Hospital, ការិយាល័យជំនួយគាំទ្រអ្នកជំងឺ 593 Eddy Street, Providence, RI 02903
   - មន្ទីរពេទ្យ Miriam Hospital, ការិយាល័យជំនួយគាំទ្រអ្នកជំងឺ 164 Summit Avenue, Providence, RI 02906
   - មន្ទីរពេទ្យ Newport Hospital ការិយាល័យជំនួយគាំទ្រអ្នកជំងឺ 11 Friendship Street, Newport, RI 02840
   - មន្ទីរពេទ្យ Bradley Hospital សេវាកម្មហិរញ្ញវត្ថុអ្នកជំងឺ 1011 Veterans Memorial Parkway, East Providence, RI 02915

   FAP របស់ Lifespan ក៏អាចរកបានផងដែរតាមរយៈការស្នើសុំតាមប្រៃសណីយ៍ដោយប្រើប្រាស់អាសយដ្ឋានស្ថាប័នមន្ទីរពេទ្យណាមួយក្នុងចំណោមអាសយដ្ឋានស្ថាប័នមន្ទីរពេទ្យដែលត្រូវបានរាយនាមខាងលើ។ អ្នកជំងឺក៏អាចចូលមើលគេហទំព័រ https://www.lifespan.org/financial-assistance-0 ផងដែរដើម្បីទទួលបានព័ត៌មាន និងទម្រង់បែបបទដែលចាំបាច់ទាំងអស់។ សំណើរសុំឲ្យផ្ញើឯកសារតាម

ប្រៃសណីយ៍អាចធ្វើឡើងបានដោយហៅទូរស័ព្ទទៅកាន់ការិយាល័យសេវាកម្មហិរញ្ញវត្ថុអ្នកជំងឺរបស់ Lifespan តាមរយៈលេខ 401-444-6949។

2. ផ្ញើតាមប្រៃសណីយ៍នូវពាក្យសុំដែលត្រូវបានបំពេញសព្វគ្រប់ ឬយកទៅជូនដោយផ្ទាល់ (ដោយមានរាល់គ្រប់ឯកសារ/ព័ត៍មានទាំងអស់ដែលត្រូវបានបញ្ជាក់នៅក្នុងសេចក្ដីណែនាំរបស់ពាក្យសុំ) ទៅកាន់អាសយដ្ឋានស្ថាប័នមន្ទីរពេទ្យរបស់ Lifespan ណាមួយដែលត្រូវបានរាយនាមខាងលើ។

Lifespan បកប្រែ FAP ទម្រង់បែបបទដាក់ពាក្យសុំ FAP និងសេចក្ដីសង្ខេបជាភាសាសាមញ្ញនៃ FAP របស់ខ្លួនទៅជាភាសាទីមួយរបស់ប្រជាជនដែលមានសមត្ថភាពផ្នែកភាសាអង់គ្លេសមានកម្រិតដែលតំណាងឲ្យប្រជាពលរដ្ឋតិចជាង 5% ឬ 1000 នាក់នៃសហគមន៍ដែលត្រូវបានបម្រើដោយស្ថាប័នមន្ទីរពេទ្យ។ ព័ត៍មានទាំងអស់មាននៅលើគេហទំព័រតាមអាសយដ្ឋាន https://www.lifespan.org/financial-assistance - ឬនៅស្ថាប័នមន្ទីរពេទ្យ Lifespan ដែលត្រូវបានរាយនាមកាលពីមុនមកនេះ។

ចំពោះជំនួយ ឬសំណួរបន្ថែមទៀត សូមហៅទូរស័ព្ទទៅកាន់ផ្នែកសេវាកម្មហិរញ្ញវត្ថុអ្នកជំងឺរបស់ Lifespan តាមរយៈលេខ 401-444-6949។ ប្រសិនបើមកដល់ដោយផ្ទាល់ សូមចូលមកមើលទីតាំងស្ថាប័នមន្ទីរពេទ្យ Lifespan ណាមួយដែលមានរាយនាមខាងលើនៅចន្លោះម៉ោង 8:00 ព្រឹក-4:00 ល្ងាច ពីថ្ងៃច័ន្ទរហូតដល់ថ្ងៃសុក្រ។